ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៧០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៥៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)

- យោងតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចុះបញ្ជី ការបង់ភាគទាន ការទាមទារ និងការផ្តល់តាវកាលិករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ៖

១- បុគ្គលស្វ័យនិយោជន៍

២- អ្នកក្នុងបន្ទុកសមាជិក **ប.ស.ស**. ដែលរួមមាន៖

- សហព័ទ្ធ និង
- កូនក្នុងបន្ទុក។

**មាត្រា៣ .-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

- កូនក្នុងបន្ទុក — សំដៅដល់កូនបង្កើតដែលមានសំបុត្របញ្ជាក់កំណើត ឬកូនសុំដែលបានសុំស្របតាមបទប្បញ្ញត្តិជាធរមាន ឬក្មេងកំព្រារស់នៅក្នុងបន្ទុកផ្ទាល់របស់សមាជិក **ប.ស.ស**. និងមានអាយុក្រោម១៨ឆ្នាំ ព្រមទាំងពុំមានប្រកបមុខរបរ ឬការងារដែលមានប្រាក់ចំណូលវៀរលែងតែកូនមានពិការភាព ឬមានជំងឺរ៉ាំរ៉ៃដែលនៅក្នុងបន្ទុកផ្ទាល់។

- បុគ្គលស្វ័យនិយោជន៍ — សំដៅដល់ជនដែលប្រកបការងារ ឬមុខរបររកចំណូលផ្ទាល់ខ្លួន ដោយមិនពាក់ព័ន្ធនឹងប្រាក់ឈ្នួល ឬបៀវត្សដែលផ្តល់ដោយនិយោជក ឬរដ្ឋតាមកិច្ចសន្យាការងារ ហើយក៏មិនមានការប្រើប្រាស់កម្មករនិយោជិតនៅក្នុងសកម្មភាពការងារឬមុខរបររបស់ខ្លួន។

- ប្រាក់បំណាច់មាតុភាព — សំដៅដល់ប្រាក់ឧបត្ថម្ភដល់សមាជិក **ប.ស.ស**. សម្រាប់រយៈពេលនៃការឈប់សម្រាកមុន និងក្រោយសម្រាលកូន។

| | |
|---|---|
| - សហព័ទ្ធ | សំដៅដល់ប្តីឬប្រពន្ធ ឬទាំងប្តីទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ |
| - របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត | សំដៅដល់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពដែលបុគ្គលស្វ័យនិយោជន៍និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ស្ម័គ្រចិត្តចូលរួមតាមរយៈការបង់ភាគទានដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។ |

## ជំពូកទី២
## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចុះបញ្ជី និងការបង់ភាគទាន
### ផ្នែកទី១
### ការចុះបញ្ជី

**មាត្រា៤ .-**

បុគ្គលស្វ័យនិយោជន៍ដែលមានអាយុមិនលើស ៦០(ហុកសិប)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទស្នើសុំចុះបញ្ជី មានសិទ្ធិចុះបញ្ជីក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត។ការចុះបញ្ជីនេះ សាមីជនត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

**មាត្រា៥ .-**

សមាជិក **ប.ស.ស**. ជាបុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបុគ្គលស្វ័យនិយោជន៍ ដែលកំពុងបង់ភាគទាន មានសិទ្ធិស្នើសុំចុះបញ្ជីអ្នកក្នុងបន្ទុកខ្លួនក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត។

សហព័ទ្ធរបស់សមាជិក **ប.ស.ស**. អាចស្នើសុំចុះបញ្ជីក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត លុះត្រាតែពុំមែនជាសមាជិក **ប.ស.ស**. ក្នុងវិស័យសាធារណៈ ឬបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឬបុគ្គលស្វ័យនិយោជន៍។

បែបបទនៃការចុះបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម៖

១-ចំពោះសហព័ទ្ធ

- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ។

២-ចំពោះកូនក្នុងបន្ទុក

- សេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត
- និង/ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ។

ក្នុងករណីអ្នកក្នុងបន្ទុកមានចំនួនចាប់ពី២(ពីរ)នាក់ឡើង ដែលបំពេញគ្រប់លក្ខខណ្ឌ ការស្នើសុំចុះបញ្ជីតម្រូវឱ្យចុះទាំងអស់។

**មាត្រា៦ .-**

បុគ្គលស្វ័យនិយោជន៍ត្រូវបំពេញសលាកបត្រព័ត៌មានសមាជិក **ប.ស.ស**.។ **ប.ស.ស**. ត្រូវចេញ បណ្ណសមាជិក **ប.ស.ស**. ជូនបុគ្គលស្វ័យនិយោជន៍ដោយអនុលោមតាមទិន្នន័យក្នុង អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

អ្នកក្នុងបន្ទុកសមាជិក **ប.ស.ស**. ត្រូវបំពេញសលាកប័ត្រព័ត៌មានសមាជិក **ប.ស.ស**.។ **ប.ស.ស**. ត្រូវចេញបណ្ណសមាជិក **ប.ស.ស**. ជូនអ្នកក្នុងបន្ទុក ដោយអនុលោមតាមទិន្នន័យក្នុង អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត។

បណ្ណសមាជិក **ប.ស.ស**. សម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក **ប.ស.ស**. ត្រូវផ្ដល់ជូនដោយឥតគិតថ្លៃ។ ក្នុងករណីបាត់ ឬខូចខាត សមាជិក **ប.ស.ស**. ត្រូវស្នើសុំបណ្ណទុតិយតាយ៉ាងយូរ៣០(សាមសិប)ថ្ងៃ។

ការផ្ដល់បណ្ណទុតិយតានេះ សាមីជនត្រូវបង់ប្រាក់ចំនួន ៥ ០០០(ប្រាំពាន់)រៀល ជូនទៅ **ប.ស.ស**.។

ទម្រង់នៃការចុះបញ្ជី ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី២
## ការបង់ភាគទាន

**មាត្រា៧ .-**

ភាគទានក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវគណនាតាមកម្រិតអប្បបរមានៃប្រាក់ចំណូល និង/ឬកម្រិតប្រាក់ចំណូលតាមប្រភេទមុខរបរ ឬការងាររបស់មេគ្រួសារ ដែលកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៨ .-**

ការបង់ភាគទាន ត្រូវធ្វើឡើងជាប្រចាំខែយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥(ដប់ប្រាំ)នៃខែបន្ទាប់។ ករណីសមាជិកមានលទ្ធភាពបង់ភាគទានប្រចាំឆ្នាំ សមាជិកនោះ ត្រូវស្នើសុំមក **ប.ស.ស**.។ ការបង់ភាគទានប្រចាំឆ្នាំតាមការស្នើសុំនេះ ត្រូវធ្វើឡើងនៅខែបន្ទាប់ គិតចាប់ពីកាលបរិច្ឆេទនៃខែដែលបានស្នើសុំបង់ភាគទាន។

ការបង់ភាគទាន ត្រូវធ្វើដោយផ្ទាល់ ឬតាមរយៈធនាគារដៃគូ ឬតាមមធ្យោបាយផ្សេងទៀត តាមការកំណត់របស់អគ្គនាយក **ប.ស.ស**.។

## ជំពូកទី៣
## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការទាមទារ និងការផ្តល់តាវកាលិក
## ផ្នែកទី១
## ការទាមទារតាវកាលិក

**មាត្រា៩ .-**

តាវកាលិករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវកំណត់តាមកម្រិតដូចខាងក្រោម៖

១- កម្រិតទី១៖ តាវកាលិកអប្បបរមា ដែលរួមមានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ប្រាក់បំណាច់មាតុភាព និងវិភាជន៍បូជាសព

២- កម្រិតទី២៖ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺបន្ថែមលើ តាវកាលិកអប្បបរមាដូចមានកំណត់ក្នុងចំណុចទី១ នៃមាត្រានេះ។

**មាត្រា១០ .-**

សមាជិក **ប.ស.ស**. មានសិទ្ធិទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រដោយ មិនបាច់បង់ថ្លៃនៅតាមមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**. លុះត្រាតែសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានចុះបញ្ជីជាសមាជិក **ប.ស.ស**.
- បានបង់ភាគទាន២(ពីរ)ខែជាប់គ្នា។

ក្នុងករណីខកខានបង់ភាគទាន សមាជិកមានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំ វេជ្ជសាស្ត្ររយៈពេល២(ពីរ)ខែបន្ថែមទៀត គិតចាប់ពីខែដែលខកខានបង់ភាគទានចុងក្រោយ។

ចំពោះការខកខានបង់ភាគទាន ហើយអស់សុពលភាពក្នុងការប្រើប្រាស់សេវា ព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សមាជិកត្រូវបង់រំលឹកភាគទានទៅតាមចំនួនខែដែលខកខាន និងត្រូវបង់ភាគទាន២(ពីរ)ខែជាប់គ្នាទៀត ទើបមានសិទ្ធិចូលប្រើប្រាស់សេវាព្យាបាលនិង ថែទាំវេជ្ជសាស្ត្រ ។

យន្តការបង់រំលឹកភាគទានក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទាន ដោយស្ម័គ្រចិត្ត ពុំត្រូវរាប់បញ្ចូលរយៈពេលនៅមានសុពលភាពនៃការចូលរួមក្នុងរបបសន្តិសុខ សង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ចឡើយ។

សមាជិក **ប.ស.ស**. ដែលបានបំពេញលក្ខខណ្ឌខាងលើ មានសិទ្ធិទទួលការព្យាបាល នៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**. ត្រឹមរយៈពេល១៨០ (មួយរយប៉ែតសិប)ថ្ងៃ ក្នុងអំឡុងពេល១២(ដប់ពីរ)ខែ ដោយគិតតែរយៈពេលព្យាបាលដែល សម្រាកនៅក្នុងមន្ទីរពេទ្យ។

**មាត្រា១១ .-**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបប ភាគទានដោយស្ម័គ្រចិត្ត មានដូចខាងក្រោម៖

១. ការផ្តល់សេវាព្យាបាលដោយសម្រាកក្នុងមូលដ្ឋានសុខាភិបាលដែលរួមមាន៖

- សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត

- ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការ ចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់សម្រាកព្យាបាល។

២.ការផ្តល់សេវាពិគ្រោះជំងឺក្រៅដែលរួមមាន៖

- សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខាផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការ ចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា។

៣. ការផ្តល់សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាល។

៤. ការផ្តល់សេវាព្យាបាលដោយស្តំ ដោយចលនា ឬសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ដទៃទៀត។

៥.ការផ្តល់សេវាសង្គ្រោះបន្ទាន់។ ក្នុងករណីសង្គ្រោះបន្ទាន់សាមីជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលស្ថិតនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះមិនមានកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**. សាមីជន ឬអ្នកតំណាងត្រូវជូនដំណឹងមក **ប.ស.ស**. ជាបន្ទាន់។

៦. សេវាបង្ការសុខភាព។

៧. សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងសេវាបញ្ជូនសព។

**មាត្រា១២ .-**

សមាជិក **ប.ស.ស**. ដែលមានគភ៌ចាប់ពី២៦(ម្ភៃប្រាំមួយ)សប្តាហ៍ឡើង និងបានបង់ភាគទាន៩(ប្រាំបួន)ខែក្នុងអំឡុងពេល១២(ដប់ពីរ)ខែចុងក្រោយ គិតមកត្រឹមទល់កាលបរិច្ឆេទសម្រាលកូនមានសិទ្ធិទទួលបានប្រាក់បំណាច់មាតុភាព។

ប្រាក់បំណាច់មាតុភាព (ប.ប.ម.) ត្រូវផ្តល់ជូន ដោយគណនាតាមកម្រិតនៃប្រាក់ចំណូលមធ្យមប្រចាំថ្ងៃដែលបានបង់ភាគទានរបស់សាមីជន( ប.ច.ម.)តាមរូបមន្ត ដូចខាងក្រោម៖

ប.ប.ម.= ៧០% × ប.ច.ម. × ៩០ថ្ងៃ

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលព្យាបាលជំងឺ ត្រូវបានផ្តល់ជូនសមាជិក **ប.ស.ស**. ដែលបានអាក់ខានការងារចាប់ពី៨(ប្រាំបី)ថ្ងៃឡើង ដោយសារការសម្រាកព្យាបាលថែទាំជំងឺ ឬរបួសតាមវេជ្ជបញ្ជានៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**.។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ (ប.ប.ព.) ត្រូវផ្តល់ជូនដោយគណនាតាមចំនួនថ្ងៃឈប់សម្រាកព្យាបាល (ច.ព.) និងប្រាក់ចំណូលមធ្យមប្រចាំថ្ងៃដែលបានបង់ភាគទានរបស់សាមីជន (ប.ច.ម.)តាមរូបមន្ត ដូចខាងក្រោម៖

ប.ប.ព.= ៧០% × ប.ច.ម. × ច.ព.

ប.ច.ម. គឺជាផលចែកនៃប្រាក់ចំណូលជាប់ភាគទានខែចុងក្រោយមុនសម្រាលកូន ឬសម្រាកព្យាបាល ចែកនឹង៣០(សាមសិប)ថ្ងៃ។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺត្រូវផ្តល់ជូនមិនលើសពី ១៨០ (មួយរយប៉ែតសិប)ថ្ងៃក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយ ដោយគិតចាប់ពីកាលបរិច្ឆេទមានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ។

**មាត្រា១៣ .-**

សិទ្ធិវន្ត ឬអ្នកចាត់ចែងបូជាសពសមាជិក **ប.ស.ស**. ក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តមានសិទ្ធិទទួលបានវិភាជន៍បូជាសព។

វិភាជន៍បូជាសពក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមការស្នើសុំរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**. ។

**មាត្រា១៤ .-**

សេវាឬការព្យាបាលដែលមិនរាប់បញ្ចូលក្នុងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្ររួមមាន៖

- ការព្យាបាលដោយមិនគិតថ្លៃ ដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
- ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
- ការព្យាបាល និងការវះកាត់ប្តូរភេទ
- ការផ្សាំឬប្តូរសរីរាង្គផ្សេងៗ
- សេវាបង្កកំណើតដោយសិប្បនិម្មិត
- ការព្យាបាលដោយខ្លួនឯង
- ការព្យាបាលឬវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាង្គកាយ
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែរ
- ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
- ការព្យាបាលអសមត្ថភាពផ្តល់កំណើត
- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
- ការវះកាត់បេះដូង និងសសៃឈាមបេះដូង
- ការលាងឈាម
- ការពិនិត្យសុខភាពទូទៅ។

សេវា ឬការព្យាបាលដូចមានចែងក្នុងវាក្យខណ្ឌទី១នៃមាត្រានេះ នឹងត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ប៉ុណ្ណោះ។

**មាត្រា១៥ .-**

ជំងឺរ៉ាំរ៉ៃក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តត្រូវកំណត់ដូចខាងក្រោម៖

- ជំងឺខ្សោយបេះដូង (Cardiac Failure)
- ជំងឺសាច់ដុំបេះដូង (Cardiomyopathy)
- ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ (Chronic Hepatitis B)
- ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis C)
- ជំងឺតម្រងនោមរ៉ាំរ៉ៃ (Chronic renal Disease)

- ជំងឺក្រិនថ្លើម (Cirrhosis of the liver )
- ជំងឺសសៃឈាមក្រហមបេះដូង (Coronary Artery Disease)
- ជំងឺវិបត្តិចង្វាក់បេះដូង ( Dysrhythmias)
- ជំងឺក្រិនសរីរាង្គ ( Multiple Sclerosis)
- ជំងឺវិកលចរិក (Schizophrenia)
- ជំងឺលុយពុស (Systemic Lupus Erythematosus)
- ជំងឺតាឡាសេមី (Thalassemia)។

ការផ្តល់សេវាចំពោះជំងឺរ៉ាំរ៉ៃ ត្រូវធ្វើឡើងតែក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និងត្រូវប្រើប្រាស់ឱសថសារវន្តតែប៉ុណ្ណោះ។ ឱសថព្យាបាលក្រៅពីក្នុងបញ្ជីឱសថសារវន្ត គឺជាបន្ទុកចំណាយផ្ទាល់របស់អ្នកជំងឺ វៀរលែងតែករណីសង្គ្រោះបន្ទាន់។

ឱសថព្យាបាលជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម ដែលមិនមាននៅក្នុងបញ្ជីឱសថសារវន្ត និងការព្យាបាលជំងឺមហារីកដោយសារធាតុគីមី ត្រូវទូទាត់ថ្លៃតាមសេវាព្យាបាលនីមួយៗ។

## ផ្នែកទី២
## ការផ្តល់តាមការលិក

**មាត្រា១៦ .-**

ទម្រង់បែបបទ និងនីតិវិធីនៃការទាមទារសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រក្នុងករណីសង្គ្រោះបន្ទាន់ ប្រាក់បំណាច់មាតុភាព វិភាជន៍បូជាសព និងប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ ត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស**.។

សិទ្ធិនៃការទាមទារសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រក្នុងករណីសង្គ្រោះបន្ទាន់ ប្រាក់បំណាច់មាតុភាព និងវិភាជន៍បូជាសព មានអាជ្ញាយុកាលត្រឹមរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាព ឬសម្រាលកូន ឬទទួលមរណភាពរបស់សាមីជន។

**មាត្រា១៧ .-**

យន្តការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវកំណត់តាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤
## សហាទិចាន

**មាត្រា១៨ .-**

សមាជិក **ប.ស.ស**. ដែលអស់លទ្ធភាពបង់ភាគទាន ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរឬតាមរយៈកម្មវិធីទូរសព្ទដៃ "សមាជិក **ប.ស.ស**. (NSSF Member APP)" អំពីការខកខាននេះមក **ប.ស.ស**. ដោយមានហេតុផលសមរម្យ។ ករណីមិនបានជូនដំណឹងត្រូវបានចាត់ទុកថាសាមីខ្លួនស្ម័គ្រចិត្តបោះបង់សិទ្ធិចូលរួមក្នុងរបបសន្តិសុខសង្គមតាមរបបភាគទានដោយស្ម័គ្រចិត្ត។

រយៈពេលនៃការខកខានបង់ភាគទានមិនត្រូវលើសពី ៦(ប្រាំមួយ)ខែ។

**មាត្រា១៩ .-**

សមាជិក **ប.ស.ស**. ជាបុគ្គលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដែលបាត់បង់ការងារក្រោយពេលចុះបញ្ជីអ្នកក្នុងបន្ទុករួច មានសិទ្ធិចូលរួមក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត។

**មាត្រា២០ .-**

សមាជិក **ប.ស.ស**. ដែលបាត់បង់ការងារមុនអាយុ៦០(ហុកសិប)ឆ្នាំ និងបានស្នើសុំចុះបញ្ជីក្នុងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ដូចមានចែងក្នុងមាត្រា៣៨ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវស្ថិតនៅក្រោមវិសាលភាពនៃអនុក្រឹត្យនេះ។

**មាត្រា២១ .-**

ការបញ្ជាក់ស្ថានភាពពិការរបស់អ្នកក្នុងបន្ទុកសមាជិក **ប.ស.ស**. ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការបញ្ជាក់ស្ថានភាពជំងឺរ៉ាំរ៉ៃរបស់អ្នកក្នុងបន្ទុកសមាជិក **ប.ស.ស**. ត្រូវកំណត់ដោយគ្រូពេទ្យដែលបម្រើការងារនៅមូលដ្ឋានសុខាភិបាលសាធារណៈឬឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងជាដៃគូ **ប.ស.ស**.។

**មាត្រា២២ .-**

ក្នុងអំឡុងពេលសម្រាកមាតុភាព សមាជិក **ប.ស.ស**. មានកាតព្វកិច្ចបង់ភាគទានបន្តមក **ប.ស.ស**.។

**មាត្រា២៣ .-**

ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវត្រួតពិនិត្យនិងវិភាគឡើងវិញជារៀងរាល់ឆ្នាំ។

**មាត្រា២៤ .-**

ប្រាក់ត្រៀមបម្រុងអប្បបរមាផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវកំណត់ស្មើនឹងប្រាក់ចំណាយសម្រាប់តាវកាលិកផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តក្នុងកំលុងពេល១(មួយ)ឆ្នាំចុងក្រោយ។

**មាត្រា២៥ .-**

កាលបរិច្ឆេទនៃការចាប់ផ្តើមអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# ជំពូកទី៥
# អវសានប្បញ្ញត្តិ

**មាត្រា២៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហ ៩ កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិតនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ហេង សួរ**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិតនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ